# សៀវភៅមគ្គុទ្ទេសក៍
# សម្រាប់ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់
# ពីធនាគារជាតិនៃកម្ពុជា
# តាមរយៈសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

# អារម្ភកថា

អនុលោមតាមអនុសាសន៍ណែនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីពី **“សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច (CamDX) ”** ធនាគារជាតិនៃកម្ពុជា បានរៀបចំសៀវភៅមគ្គុទ្ទេសក៍សម្រាប់ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ ក្នុងគោលដៅដើម្បីរួមចំណែកជួយសម្រួលដល់ការបង្កើតអាជីវកម្ម លើកកម្ពស់បរិយាកាសធុរកិច្ច និងបង្កើនការវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈប្រព័ន្ធនេះ ធុរកិច្ចជននៅរាជធានី និងបណ្តាខេត្តនានា អាចធ្វើការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់បានងាយស្រួល និងឆាប់រហ័ស។

សៀវភៅមគ្គុទ្ទេសក៍សម្រាប់ការស្នើសុំអាជ្ញាបណ្ណនេះ ត្រូវបានរៀបចំឡើង ដើម្បីជំរុញឱ្យការប្រើប្រាស់ប្រព័ន្ធនេះ ប្រព្រឹត្តទៅដោយរលូន និងកាន់តែមានប្រសិទ្ធភាព។ ជាមួយគ្នានេះ សៀវភៅនេះក៏បានបង្ហាញពីនីតិវិធីនៃការចូលទៅប្រើប្រាស់ប្រព័ន្ធតាមដំណាក់កាលនីមួយៗផងដែរ។

# មាតិកា

១- ព័ត៌មានទូទៅ

១-១ ហេតុអ្វីត្រូវស្នើសុំអាជ្ញាបណ្ណ ........................................................... ០៣

១-២ ទិដ្ឋភាពទូទៅនៃការស្នើសុំអាជ្ញាបណ្ណ ................................................ ០៤

២- របៀបដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ

២-១ របៀបចូលទៅក្នុងគេហទំព័រ.............................................................. ០៧

២-២ របៀបស្នើសុំអាជ្ញាបណ្ណ .................................................................. ០៩

៣- របៀបពិនិត្យមើលបង្កាន់ដៃបង់សោហ៊ុយសិក្សាសំណុំលិខិត .............................. ១៤

៤- ការបញ្ជូនត្រលប់ពីមន្ត្រីជំនាញ ............................................................... ១៥

៥- របៀបបង់ប្រាក់តម្កល់ដើមទុន និងសោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ ........................ ១៦

៦- របៀបតាមដានវឌ្ឍនភាពលើការស្នើសុំ ..................................................... ១៩

៧- ពត៌មានផ្សេងៗ ..................................................................................... ២០

## ហេតុអ្វីត្រូវស្នើសុំអាជ្ញាបណ្ណ?

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ គ្រប់រូបវន្តបុគ្គល/នីតិបុគ្គល ដែលប្រកបអាជីវកម្មប្តូរប្រាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ពីធនាគារជាតិនៃកម្ពុជា។

ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ទទួលបាននូវអត្ថប្រយោជន៍ ដូចខាងក្រោម៖

- ទទួលបានសិទ្ធស្របច្បាប់ក្នុងការប្រកបអាជីវកម្មប្តូរប្រាក់
- មានសិទ្ធចូលរួមក្នុងការទិញ-លក់ប្រាក់រៀលក្នុងប្រព័ន្ធធនាគារ (NBCP Platform)
- មានសិទ្ធចូលរួមក្នុងការដេញថ្លៃទិញ-លក់ប្រាក់រៀលជាមួយធនាគារជាតិនៃកម្ពុជា និង
- ទទួលបានការបណ្តុះបណ្តាលពីធនាគារជាតិនៃកម្ពុជាទាក់ទងនឹងរូបិយបណ្ណក្លែងក្លាយ។

បន្ថែមលើអត្ថប្រយោជន៍ដូចបានរៀបរាប់ខាងលើ ការស្នើសុំអាជ្ញាបណ្ណតាមរយៈសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច (CamDX) មានអត្ថប្រយោជន៍ដូចខាងក្រោមៈ

- ផ្តល់ទំនុកចិត្ត និងភាពងាយស្រួលដល់អាជីវករប្តូរប្រាក់
- ចំណេញពេលវេលា និងកាត់បន្ថយបន្ទុកចំណាយផ្សេងៗ
- ប្រកបសកម្មភាពអាជីវកម្មត្រឹមត្រូវស្របតាមបែបបទ នីតិវិធី និងសេចក្តីណែនាំ
- ចូលរួមចំណែកប្រតិបត្តិតាមអភិបាលកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច និងលើកកម្ពស់ការអភិវឌ្ឍន៍វិស័យទាំងមូលប្រកបដោយចីរភាព និង
- ទទួលបានសិទ្ធ កាតព្វកិច្ច និងការការពារដោយច្បាប់។

# <u>ទិដ្ឋភាពទូទៅនៃការស្នើសុំអាជ្ញាបណ្ណ</u>

# <u>តាមរយៈសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច</u>

អាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ សំដៅដល់លិខិតគតិយុត្តដែលចេញដោយធនាគារជាតិនៃកម្ពុជា ដើម្បីអនុញ្ញាតឱ្យរូបវន្តបុគ្គល/នីតិបុគ្គល ប្រកបអាជីវកម្មប្តូរប្រាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## <u>ឯកសារតម្រូវ</u>

រាល់ឯកសារទាំងអស់ត្រូវស្កិតនៅក្នុងទម្រង់ជា PDF រីឯរូបថតត្រូវស្កិតក្នុងទម្រង់ JPG ឬ JPEG ដែលស្កេនពីច្បាប់ដើម ហើយមានគុណភាពល្អ។ សូមបញ្ជាក់ថា ប្រសិនបើលោកអ្នកមិនផ្តល់ឯកសារ ឬព័ត៌មានគ្រប់គ្រាន់ ពិតប្រាកដ និងច្បាស់លាស់ ក្នុងពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកធនាគារជាតិនៃកម្ពុជា តាមរយៈសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច នោះសំណើសុំអាជ្ញាបណ្ណរបស់លោកអ្នកនឹងត្រូវបានបដិសេធ។

ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ ត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់របស់ក្រុមហ៊ុន (ច្បាប់ដើម)
- គោលបំណងនៃការធ្វើប្រតិបត្តិការប្តូរប្រាក់ និងប្រភេទរូបិយបណ្ណ
- លក្ខន្តិកៈក្រុមហ៊ុន (ច្បាប់ចម្លង)
- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម (ច្បាប់ចម្លង)
- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីពន្ធដារ/ពន្ធប៉ាតង់ (ច្បាប់ចម្លង)
- ឈ្មោះ/កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនត្រូវទាក់ទងនឹងអាជីវកម្មប្តូរប្រាក់
- កិច្ចសន្យាចូលហ៊ុនរបស់ភាគទុនិក (ច្បាប់ដើម)។ លិខិតធានាលើភាពត្រឹមត្រូវនៃការចូលហ៊ុនគ្នាក្នុងការបង្កើតក្រុមហ៊ុន (ច្បាប់ដើម) ក្នុងករណីមិនមានកិច្ចសន្យាចូលហ៊ុនរបស់ភាគទុនិកច្បាប់ដើម
- របាយការណ៍ហិរញ្ញវត្ថុរយៈពេល៣ឆ្នាំ (ច្បាប់ចម្លង)
- របាយការណ៍គណនីធនាគាររបស់ភាគទុនិក រយៈពេល២ឆ្នាំ សម្រាប់ក្រុមហ៊ុនបង្កើតថ្មី (ច្បាប់ដើម)
- លក្ខន្តិកៈ និងវិញ្ញាបនបត្រក្រុមហ៊ុនដែលភាគទុនិកមានក្រុមហ៊ុនផ្សេងៗទៀត (ច្បាប់ចម្លង)
- កិច្ចសន្យាការងារ ឬលិខិតបញ្ជាក់ពីស្ថាប័នពាក់ព័ន្ធ
- ករណីភាគទុនិកជានីតិបុគ្គលត្រូវភ្ជាប់លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុននោះ

- កំណត់ហេតុប្រជុំ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬម្ចាស់ភាគហ៊ុនស្តីពីការបង្កើតអាជីវកម្មប្តូរប្រាក់ (សម្រាប់ក្រុមហ៊ុនដែលមានភាគទុនិកចាប់ពី ២នាក់ឡើងទៅ)
- ប្រវត្តិរូប សង្ខេប មានបិទរូបថតទំហំ ៤x៦ (ត្រូវបញ្ជាក់ពីសាការី)
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ និងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់ភាគទុនិក (ច្បាប់ចម្លង)
- លិខិតថ្កោលទោសរបស់ភាគទុនិក (ច្បាប់ដើម)
- ប័ណ្ណ និងសៀវភៅការងារ ជនបរទេស (ច្បាប់ចម្លង)
- លិខិតអះអាងពីប្រភពទុន និងការបង្កើតអាជីវកម្មរបស់ខ្លួនដែលបញ្ជាក់ថា មិនមែនជាការឈរឈ្មោះឱ្យបុគ្គលផ្សេង (បញ្ជាក់ពីសារការី)
- កិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម ឬបណ្ណកម្មសិទ្ធិ (ទីតាំងផ្ទាល់ខ្លួន)
- រូបថតទីតាំងប្រកបអាជីវកម្មដោយមានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន
- បង្កាន់ដៃបង់ប្រាក់ចំនួន ២០០.០០០ រៀល ចូលគណនី ៧៣១២០១១២៦ សម្រាប់សោហ៊ុយសិក្សាសំណុំលិខិត (ច្បាប់ដើម) និង
- ឯកសារផ្សេងៗទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

## **<u>តារាងតម្លៃ</u>**

តម្លៃអាជ្ញាបណ្ណ និងសុពលភាពអាជ្ញាបណ្ណដែលកំណត់ដោយធនាគារជាតិនៃកម្ពុជាៈ

| **បរិយាយ** | **ចំនួនទឹកប្រាក់** | **គណនីត្រូវបង់ចូល** |
|---|---|---|
| សោហ៊ុយសិក្សាសំណុំលិខិត | ២០០.០០០ រៀល | ៧៣១២០១១២៦ |
| សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ | ១០.០០០.០០០ រៀល | ៧៣១១០២០០០ |
| ប្រាក់តម្កល់ធានាលើដើមទុន | ៨០.០០០.០០០ រៀល | |
| សុពលភាពអាជ្ញាបណ្ណរយៈពេល ៣ឆ្នាំ | | |

* ធនាគារជាតិនៃកម្ពុជារក្សាសិទ្ធក្នុងការកែប្រែតម្លៃខាងលើតាមការចាំបាច់។

# ទម្រង់អាជ្ញាបណ្ណ



ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA
លេខ : អ.ប.០៩៧
Nº : L.X.097

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

## អាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់
## LICENSE TO CONDUCT MONEY EXCHANGE BUSINESS

**ធនាគារជាតិ នៃ កម្ពុជា**

អនុញ្ញាតឱ្យ [redacted] ធ្វើអាជីវកម្មប្តូរប្រាក់ ដែលមានទីស្នាក់ការកណ្តាលតាំងនៅ អគារលេខ៨៨ ផ្លូវលេខ២១៤ កែងផ្លូវលេខ១១៣ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

[redacted] ត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ និងបទប្បញ្ញត្តិ សារាចរណែនាំ វិធាន ព្រមទាំងលក្ខខណ្ឌទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា។

**THE NATIONAL BANK OF CAMBODIA**

allows [redacted] to carry out money changing business with head office at Building Nº 88, Street Nº 214 Corner Street Nº 113, Sangkat Boeng Proluet, Khan Prampir Meakkakra, Phnom Penh.

[redacted] shall abide by the Law on Foreign Exchange and all regulations, circulars, rules, and conditions issued by the National Bank of Cambodia.

ថ្ងៃព្រហ ៤រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤
Phnom Penh, 29 February 2024

ជ. ទេសាភិបាល
FOR GOVERNOR

រ័ត្ន សុវណ្ណនះ

- អាជ្ញាបណ្ណនេះ មានសុពលភាពរហូតដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៧
- អាជ្ញាបណ្ណនេះ ត្រូវតែបង្ហាញសាធារណជនគ្រប់ពេលវេលា

- This license is valid until 01 February 2027
- This license shall be displayed to the public at all times.

# <u>របៀបចូលក្នុងគេហទំព័រ</u>

១- ចូលទៅគេហទំព័រ www.registrationservices.gov.kh លើកុំព្យូទ័ររបស់អ្នក រួចចុចប៊ូតុង **“អាជ្ញាបណ្ណជំនាញ ”** នៅផ្នែកខាងលើនៃគេហទំព័រ




២- ចូលទៅកាន់ **“ធនាគារជាតិនៃកម្ពុជា ”** រួចចុច **“ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណប្តូរប្រាក់ ”**



៣- ចុចប៊ូតុង "ចូលប្រើប្រាស់ជាមួយគណនី CamDigikey"




៤- ចូលកម្មវិធីទូរស័ព្ទដៃ CamDigiKey ដើម្បីស្កែនកូដ QR ដែលបង្ហាញនៅលើផតថល



# របៀបស្នើសុំអាជ្ញាបណ្ណ

១- ចុចលើប៊ូតុង "**ពាក្យស្នើសុំ**" បន្ទាប់មកបំពេញព័ត៌មានពាក្យស្នើសុំ រួចចុច "**បន្ត**"




២- បំពេញព័ត៌មានក្រុមហ៊ុនប្តូរប្រាក់ រួចចុច "**បន្ត**"



៣- បំពេញព័ត៌មានភាគទុនិក រួចចុច "**បន្ត**"




❖ ក្នុងករណីភាគទុនិកជារូបវន្តបុគ្គល សូមចុចប៊ូតុង "**បន្ថែមរូបវន្តបុគ្គល**" រួចបំពេញព័ត៌មានទាំងអស់ និងបញ្ចូលឯកសារ រួចចុច "**រក្សាទុក**"




❖ ក្នុងករណីភាគទុនិកជានីតិបុគ្គល សូមចុចប៊ូតុង "**បន្ថែមនីតិបុគ្គល**" រួចបំពេញព័ត៌មានទាំងអស់ និងបញ្ចូលឯកសារ រួចចុច "**រក្សាទុក**"




៣- បញ្ចូលឯកសារភ្ជាប់របស់ក្រុមហ៊ុនប្តូរប្រាក់ រួចចុច "**បន្ត**"




៥- សូមពិនិត្យព័ត៌មាន និងឯកសារភ្ជាប់ឡើងវិញ រួចចុច ប៊ូតុង "**បន្ត**"




៦- ចុចប៊ូតុង "**បង់ប្រាក់**" សម្រាប់សោហ៊ុយសិក្សាសំណុំលិខិតអាជ្ញាបណ្ណប្ដូរប្រាក់




៧- ផ្ទាំង KHQR នឹងបង្ហាញលើ Screen សូមធ្វើការស្កេន QR Code ដើម្បីបង់ប្រាក់




នៅពេលការបង់ប្រាក់បានជោគជ័យ ការស្នើសុំរបស់លោកអ្នកត្រូវរង់ចាំការអនុម័តពីមន្ត្រីជំនាញដើម្បីពិនិត្យ និងធ្វើការអមុន័ត។



# របៀបពិនិត្យមើលបង្កាន់ដៃ
# បង់សោហ៊ុយសិក្សាសំណុំលិខិតសម្រាប់អាជ្ញាបណ្ណប្ដូរប្រាក់

១- ចូលទៅកាន់ "**ការស្នើទាំងអស់**" រួចជ្រើសរើសសំណើរដែលអ្នកចង់ពិនិត្យ




២- ចុចលើ ប៊ូតុងព៌ណលឿង នៅខាងស្ដាំ ដើម្បីពិនិត្យមើលបង្កាន់ដៃ



# ការបញ្ជូនត្រលប់ពីមន្ត្រីជំនាញ

❖ ក្នុងករណីពាក្យស្នើសុំមិនត្រឹមត្រូវ មន្ត្រីជំនាញនឹងបញ្ជូនត្រឡប់មកវិញ ដើម្បីអ្នកស្នើសុំធ្វើការកែតម្រូវ




❖ អ្នកស្នើសុំត្រូវធ្វើការកែតម្រូវ និងដាក់ស្នើដើម្បីពិនិត្យម្តងទៀត។
មន្ត្រីជំនាញ នឹងធ្វើការអនុម័តលើពាក្យស្នើសុំបើពិនិត្យឃើញថា ត្រឹមត្រូវ។



# របៀបបង់ប្រាក់តម្កល់ដើមទុន និងសោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ

បន្ទាប់ពីពាក្យស្នើសុំរបស់លោកអ្នកត្រូវបានអនុម័តដោយមន្ត្រីជំនាញ ពាក្យស្នើសុំរបស់លោកអ្នកនឹងលោតចេញពាក្យ "**បានអនុម័ត**"។

លោកអ្នកត្រូវបង់ប្រាក់តម្កល់ដើមទុន និងសោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ តាមជម្រើសដូច ខាងក្រោម៖

- បង់សាច់ប្រាក់នៅបេឡាធនាគារជាតិនៃកម្ពុជា
- ទូទាត់តាមរយៈគណនីដែលមាននៅនាយកដ្ឋានសេវាធនាគាររបស់ធនាគារជាតិនៃកម្ពុជា
- ទូទាត់តាមរយៈប្រព័ន្ធសេវាទូទាត់អេឡិចត្រូនិច

  បន្ទាប់ពីបង់ប្រាក់រួច លោកអ្នកត្រូវចូលទៅក្នុងប្រព័ន្ធម្តងទៀត ដើម្បីបញ្ចូលឯកសារភ្ជាប់ (វិក័យប័ត្របង់ប្រាក់ទាំង២) ចូលក្នុងប្រព័ន្ធ។

១- ចុចលើប៊ូតុង "**សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ**" ចុចលើប៊ូតុង "**បន្ថែមសោហ៊ុយអាជ្ញាបណ្ណ**"



២- បញ្ចូលឯកសារភ្ជាប់ (វិក័យប័ត្របង់ប្រាក់ទាំង២) ចូលក្នុងប្រព័ន្ធរួច ចុចលើប៊ូតុង "**រក្សាទុក**"




❖ ក្នុងករណីឯកសារសោហ៊ុយអាជ្ញាបណ្ណដែលភ្ជាប់ មិនត្រឹមត្រូវ មន្ត្រីជំនាញនឹងបញ្ជូនត្រឡប់មកវិញ ដើម្បីកែតម្រូវ



❖ លោកអ្នកត្រូវភ្ជាប់ឯកសារថ្មីម្តងទៀតឱ្យបានត្រឹមត្រូវ ដើម្បីមន្ត្រីជំនាញពិនិត្យឡើងវិញ




❖ មន្ត្រីជំនាញ នឹងអនុម័តលើពាក្យស្នើសុំ បើពិនិត្យឃើញថា ត្រឹមត្រូវ នឹងធ្វើការចេញអាជ្ញាបណ្ណ ជូនអ្នកស្នើសុំ។ លោកអ្នកអាចទាញយកអាជ្ញាបណ្ណប្តូរប្រាក់ពីប្រព័ន្ធសម្រាប់ទុកជាឯកសារ និងត្រូវទៅទទួលយកច្បាប់ដើមនៅធនាគារជាតិនៃកម្ពុជា។



# <u>របៀបតាមដានវឌ្ឍនភាពលើការស្នើសុំ</u>

❖ លោកអ្នកក៏អាចធ្វើតាមដានវឌ្ឍនភាពលើការស្នើសុំរបស់លោកអ្នក ដោយចុចលើពាក្យ "**ប្រវត្តិការត្រួតពិនិត្យ**"



# ព័ត៌មានផ្សេងៗ

សម្រាប់ការយល់ដឹងលម្អិត សូមសិក្សានូវច្បាប់ បទប្បញ្ញត្តិ ប្រកាស និងសេចក្តីណែនាំពាក់ព័ន្ធផ្សេងៗទៀត ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

លេខទំនាក់ទំនង:023 428 850 / 015 454 526

អ៊ីម៉េល: emd.info@nbc.gov.kh

គេហទំព័រ: www.nbc.gov.kh

អាស័យដ្ឋាន: 69-70, មហាវិថីហាណូយ (1019) រាជធានីភ្នំពេញ